00338864



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / JUNE / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4 ,Chaom Chau , Dangkao, Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨- កក្កដា-២០០៧-អវតក/អជសដ អនុលោម "តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី **កាំង ហ្គេកអ៊ាវ ហៅឌុច**" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច")[1]។

**ក្រោយពីបានស្តាប់** នូវសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ដែលធ្វើឡើងដោយផ្ទាល់មាត់របស់មេធាវីការពារក្តី ("សំណើ") និងសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាធ្វើនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩[2] ។

**បានឃើញ** ការបដិសេធរបស់ខ្លួនទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំធ្វើសេចក្តីសន្និដ្ឋានទាក់ទងទៅនឹងសំណើ និងសេចក្តីសម្រេចរបស់ខ្លួនបដិសេធសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលបានដាក់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ស្តីអំពីបញ្ហានេះ[3] ។

**បានឃើញ** សេចក្តីអញ្ជើញរបស់ខ្លួនដល់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសំណើរបស់មេធាវីការពារក្តីដែលលើកឡើងថា ការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធា

---

[1] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42)។

[2] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារលេខ E1/7) និងប្រតិចារិកនៃដំណើរការនីតិវិធី ("ប្រ") (ឯកសារ E1/7.1, ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ទំព័រ ២០-៣៨ (ភាសាអង់គ្លេស)។

[3] «Réponse des co-avocats des parties civiles (groupe 3) à la demande de mise en liberté de Kaing Guek Eav, alias DUCH» ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39)។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី" ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/8)។

ត្រូវយកមកពិចារណាក្នុងការផ្តន្ទាទោស ប្រសិនបើមានការផ្តន្ទាទោស ហើយថាត្រូវផ្តល់នូវការកាត់បន្ថយទោសជាសំណងចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ[4]។

**ក្រោយពីបានទទួល** សេចក្តីសង្កេតជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម៣ ដែលបានដាក់តាមកាលបរិច្ឆេទដែលបានកំណត់[5] ។

**បានឃើញ** សេចក្តីសង្កេតជាលាយលក្ខណ៍អក្សរដែលបានដាក់ជូនដោយមេធាវីការពារក្តីនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩[6] ។

**ក្រោយពីបានទទួល** សំណុំរឿងថតចម្លងមួយច្បាប់ប្រឆាំងទៅនឹងជនជាប់ចោទពីតុលាការយោធា ("សំណុំរឿងតុលាការយោធា")[7] ។

**បានឃើញ** យោបល់របស់សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៩ ទាក់ទិនទៅនឹងសំណុំរឿងតុលាការយោធា ដែលធ្វើឡើងតាមសំណើរបស់អង្គជំនុំជម្រះ[8] ។

**អនុលោមតាម** វិធាន៨២ នៃវិធានផ្ទៃក្នុង។

**ជំនុំជម្រះសម្រេច** ដូចខាងក្រោម ៖

---

[4] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/8)។

[5] «Observations supplémentaires des co-avocats des parties civiles (groupe 3) sur la demande de mise en liberté de Kaing Guek Eav, alias DUCH», ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39/1) និង "សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំឱ្យបដិសេធសំណងបន្ថែមចំពោះជនជាប់ចោទដោយសារការឃុំខ្លួនបណ្តោះអាសន្នដោយខុសច្បាប់" ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39/2)។

[6] « Arguments supplémentaires de la Défense venant au soutien de ses demandes relatives à la question de la peine », ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39/3)។

[7] ឯកសារ E52/4 និងឧបសម្ពន្ធ។

[8] "យោបល់របស់សហព្រះរាជអាជ្ញាទៅលើសំណុំរឿងតុលាការយោធា" ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារ E39/4/1) និង Observations de la défense relatives au dossier militaire ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារ E39/4/2)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

## ក. សេចក្តីផ្តើម

១. សេចក្តីសម្រេចនេះធ្វើឡើង បន្ទាប់ពីមានការតវ៉ាពីមេធាវីការពារក្តីអំពីភាពស្របច្បាប់នៃការឃុំខ្លួនជាបណ្តោះអាសន្នរបស់ជនជាប់ចោទ។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន បន្ទាប់ពីមានសវនាការតទល់គ្នា ដែលក្នុងចំណោមបញ្ហាទាំងឡាយ មេធាវីការពារក្តី បានលើកឡើងនូវទឡ្ហីករណ៍អំពីភាពមិនស្របច្បាប់នៃការឃុំខ្លួនជនជាប់ចោទ។ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានតម្កល់អំពីនីត្យានុកូលភាពនៃដីកាឃុំខ្លួនជនជាប់ចោទ។ ការតវ៉ានេះត្រូវបានធ្វើឡើងជាថ្មីទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានអះអាងថា ការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធា និងនៅ អ.វ.ត.ក គឺជាការឃុំខ្លួនបន្ត និង លើសរយៈពេលកំណត់អតិបរមានៃការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ច្បាប់និងវិធាន អ.វ.ត.ក និងបទដ្ឋានអន្តរជាតិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[9]។ មេធាវីការពារក្តី បានស្នើសុំឱ្យមានការដោះលែងជនជាប់ចោទជាបន្ទាន់ ដោយស្ថិតនៅក្រោមលក្ខខណ្ឌ ដែលអាចដាក់ចេញដោយអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្តីក៏បានស្នើសុំផងដែរឱ្យប្រកាសថាប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ពេញលេញនូវរយៈពេល ដែលខ្លួនជាប់ឃុំ បន្ថែមទៅនឹងការកាត់បន្ថយទោសជាសំណងចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ។ សំណើនោះត្រូវបានជំទាស់ត្រង់ផ្នែកខ្លះពីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។

## ខ. ប្រវត្តិនៃនីតិវិធី

[9] ប្រ. ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/7.1) ទំព័រ 20-23 (អង់គ្លេស)។

២. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩[10] ជនជាប់ចោទត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយតុលាការយោធាកម្ពុជាដោយផ្អែកលើការចោទប្រកាន់ជាច្រើនបទល្មើស អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចូលជាធរមាននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១[11]។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ និងក្រោយមកជារៀងរាល់ឆ្នាំរហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធាបានចេញដីកាឃុំខ្លួនជាច្រើន ដោយផ្អែកលើមូលដ្ឋាននៃមាត្រា៥ និងមាត្រា៣៩ នៃច្បាប់ អ.វ.ត.ក ដែលអនុលោមតាមច្បាប់នេះ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[12]។ នៅក្នុងខែ ឧសភា ឆ្នាំ២០០២ ដីកាដោះលែង

---

[10] "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" តុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ (តុលាការយោធា លេខ 012/99, ឯកសារ E52/4.3) និង "ដីកាឃុំខ្លួន" ចៅក្រមស៊ើបអង្កេតតុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ (តុលាការយោធា លេខ 142/99, ឯកសារ E52/4.8) ។ បទចោទទាំងនេះ រួមមាន "ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ក្នុងទិសដៅបម្រើឱ្យនយោបាយក្រុមកម្ពុជាប្រជាធិបតេយ្យ" ដែលត្រូវបានប្រព្រឹត្តជាមួយ អ៊ឹង ជឿង ហៅ តាម៉ុក ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អនុលោមតាមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤ និង ក្រឹត្យច្បាប់ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍ និងបណ្តាទោសនៃបទល្មើសផ្សេងៗទៀត ឆ្នាំ១៩៨០ ("ក្រឹត្យច្បាប់ លេខ២")។ បទចោទបន្ថែមទៀត រួមទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានចោទបន្ថែមក្នុងខែកញ្ញា ឆ្នាំ១៩៩៩ អនុលោមតាមមាត្រា២ នៃក្រឹត្យច្បាប់ លេខ១ ស្តីពីការបង្កើតតុលាការបដិវត្តន៍ប្រជាជននៅទីក្រុងភ្នំពេញ ដើម្បីកាត់ទោសបន ប៉ុល ពត-អៀងសារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ១៩៧៩ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ", ព្រះរាជអាជ្ញាយោធា ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩, តុលាការយោធា លេខ 044/99, ឯកសារ E52/4.26 និង "ដីកាឃុំខ្លួន" ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ តុលាការយោធា លេខ 176/99, ឯកសារ E52/4.22) (សូមអាន "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ (តុលាការយោធា លេខ140)។ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២" តុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ (តុលាការយោធា លេខ 029/99, ឯកសារ E52/4.9)។ ការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ត្រូវបានពន្យារបន្ថែមទៀតជារៀងរាល់ឆ្នាំ ក្នុងខែឧសភា ឆ្នាំ២០០០ និងឆ្នាំ២០០១ ដោយផ្អែកលើបទចោទប្រល័យពូជសាសន៍ ("សេចក្តីសម្រេចស្តីពីការពន្យាររយៈពេលស៊ើបអង្កេត") ព្រះរាជអាជ្ញាយោធា ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ តុលាការយោធា លេខ 013/2000, ឯកសារ E52/4.34) និង "សេចក្តីសម្រេចស្តីពីការពន្យាររយៈពេលស៊ើបអង្កេត" តុលាការយោធា ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ 015/2001, ឯកសារ E52/4.46)។

[11] ច្បាប់នេះ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ត្រូវបានហៅថា "ច្បាប់ អ.វ.ត.ក"។

[12] ដីកាឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ (តុលាការយោធា លេខ 16/2002DK, ឯកសារ E52/4.47) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៣ (តុលាការយោធា លេខ 10/03DK, ឯកសារ

ជនជាប់ចោទចំពោះបទល្មើសប្រល័យពូជសាសន៍ ត្រូវបានចេញដោយគ្មានប្រសិទ្ធភាព ដោយសារដីកាមុននេះសម្រេចឃុំខ្លួនជនជាប់ចោទអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[13]។

៣. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ ព្រះរាជអាជ្ញាតុលាការយោធាបានចេញ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ថ្មីមួយ[14]។ ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធាបានពន្យាររយៈពេលឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្នផ្សេងៗគ្នា នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដោយផ្អែកទៅលើការចោទប្រកាន់អំពីបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិក្រោមមាត្រា៦ និងមាត្រា៨ នៃច្បាប់ អ.វ.ត.ក[15]។ ដោយបានពិចារណាថា តុលាការយោធាមិនមានសមត្ថកិច្ចតទៅទៀតទេក្នុងការកាត់

---

E52/4.48) និងចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៤ (តុលាការយោធា លេខ 19/04/DK, ឯកសារ E52/4.54) និង "សេចក្ដីសម្រេចស្ដីពីការពន្យាររយៈពេលស៊ើបអង្កេត" ព្រះរាជអាជ្ញាយោធា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ (តុលាការយោធា លេខ 003/04, ឯកសារ E52/4.52)។

[13] "ដីកាសម្រេចឱ្យជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្ន" ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០២ (តុលាការយោធា លេខ 05/2002, ឯកសារ E52/4.55), និង "ដីកាឃុំខ្លួន" របស់ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ (តុលាការយោធា លេខ 16DK/2002DK, ឯកសារ E52/4.47)។

[14] "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ព្រះរាជអាជ្ញាយោធា ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ (តុលាការយោធា លេខ 004/05) (យោងនៅក្នុងដីការបស់ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ (តុលាការយោធា លេខ 08/05, ឯកសារ E52/4.57) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ (តុលាការយោធា លេខ 05/06/DK, ឯកសារ E52/4.60) និងចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ (តុលាការយោធា លេខ 74/07, ឯកសារ E52/4.63)។

[15] ដីកាឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ (តុលាការយោធា លេខ 08/05, ឯកសារ E52/4.57) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ (តុលាការយោធាលេខ 05/06/DK, ឯកសារ E52/4.60) និងចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ (តុលាការយោធា លេខ 74/07, ឯកសារ E52/4.63) ដោយឯកសារនីមួយៗ (យោងតម្រូវការ "អនុវត្តកិច្ចស៊ើបអង្កេត" និងផ្អែកទៅលើមាត្រា ៦ និងមាត្រា ៨ នៃច្បាប់ អ.វ.ត.ក ដែលនៅក្រោមច្បាប់នោះជនជាប់ចោទត្រូវបានចោទពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលត្រូវបានការពារជាអន្តរជាតិ)។ សូមអាន "សេចក្ដីសម្រេចពន្យាររយៈពេលស៊ើបអង្កេត" ព្រះរាជអាជ្ញាយោធា ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៦ (តុលាការយោធា លេខ 001/06, ឯកសារ E52/4.61)។

សេចក្ដីទៅលើបទឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ តុលាការឃោធាបានចេញសេចក្ដីសម្រេចបញ្ជប់សមត្ថកិច្ចរបស់តុលាការឃោធាទៅលើជនជាប់ចោទរូបនេះ[16]។

៤. ជនជាប់ចោទបានស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក ចាប់តាំងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ នៅកាលបរិច្ឆេទនោះ បន្ថែមពីលើដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញដោយ ស.ច.ស នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ជនជាប់ចោទត្រូវបានផ្ទេរពីតុលាការឃោធាមកកាន់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[17]។ នៅក្នុងសវនាការតទល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ នៅចំពោះមុខ ស.ច.ស មេធាវីការពារក្ដីបានចោទប្រកាន់ថា ការឃុំខ្លួនជនជាប់ចោទគឺមិនត្រឹមត្រូវតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ[18]។ នៅថ្ងៃដដែលនោះដែរ ស.ច.ស បានចេញដីកាឃុំខ្លួនបណ្ដោះអាសន្នសម្រាប់រយៈពេលមិនលើសពីមួយឆ្នាំ ដោយយល់ឃើញថា ពួកគាត់មិនមានយុត្តាធិការក្នុងការពិចារណាអំពីនីត្យានុកូលភាពនៃការឃុំខ្លួនជនជាប់ចោទពីមុនមកទេ។ អនុលោមតាមវិធាន៦៣ ស.ច.ស យល់ឃើញថាមានមូលដ្ឋានជឿជាក់យ៉ាងច្បាស់ថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលរូបគាត់ត្រូវបានចោទប្រកាន់ ហើយថា ការឃុំខ្លួនបណ្ដោះអាសន្នគឺចាំបាច់ដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទនៅក្នុងដំណើរការនីតិវិធី ដើម្បីធានាសុវត្ថិភាពជនត្រូវចោទ និងដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ[19]។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ស.ច.ស បានចេញដីកាបន្តឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្នរយៈពេលមួយឆ្នាំបន្ថែមទៀត ដោយផ្អែកលើការ

---

[16] "ដីកាសម្រេច" ចៅក្រមស៊ើបអង្កេតនៃតុលាការឃោធា ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ (តុលាការឃោធា លេខ 139/08/DK, ឯកសារ E52/4.66)។

[17] ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ C1)។ សូមអាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ D3) (ដោយចោទប្រកាន់ពីបទរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩) និង "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការប្រគល់ជនល្មើស" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ E52/4.65)។

[18] កំណត់ជាលាយលក្ខណ៍អក្សរនៃសវនាការសួរដេញដោល ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ C2)។

[19] ដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ C3)។ ដីកាឃុំខ្លួន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ C4)។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ចោទប្រកាន់អំពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពាន យ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ[20]។

៥. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នរបស់ ស.ច.ស[21]។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ ដោយបង្ហាញនូវសំអាងហេតុជំនួស និងបានតម្កល់ដីកាឃុំខ្លួនជនជាប់ចោទរបស់ ស.ច.ស ដោយសំអាងថា មាននូវមូលហេតុចំពោះលក្ខខណ្ឌផ្សេងៗទាំងប្រាំសម្រាប់ការឃុំខ្លួនជនជាប់ចោទតាមវិធាន ៦៣(៣)[22]។ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះបានបង្គាប់បន្ថែមថា ការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នត្រូវបន្ត រហូតដល់ជននោះបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[23]។

## គ. សេចក្តីសន្និដ្ឋាន

---

[20] "ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ (ឯកសារ C3/II)។

[21] "សារណាបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧" ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ (ឯកសារ C5/5)។ "ចម្លើយតបរបស់សហព្រះរាជអាជ្ញា តបទៅបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ដែលប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតលើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧" ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ (ឯកសារ C5/8)។

[22] "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ កាំង ហ្គេកអ៊ាវ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ (ឯកសារ C5/45)។

[23] "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42) កថាខណ្ឌ១៤៧ និង ដីកាឃុំខ្លួន ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/43)។ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ជនជាប់ចោទ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ (ឯកសារ D99)) ។ សេចក្តីសម្រេចរបស់ អ.ប.ជ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ បានចោទប្រកាន់បន្ថែមទៅលើជនជាប់ចោទពីបទរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក្រោមមាត្រា ៣ថ្មី ២៩ថ្មី និង ២៩ថ្មី និង ៣៩ថ្មី នៃច្បាប់ អ.វ.ត.ក។

៦. មេធាវីការពារក្ដីបានស្នើសុំឲ្យមានការដោះលែងជនជាប់ចោទ សម្រាប់អំឡុងពេលនៃការជំនុំជម្រះក្ដី ដោយស្ថិតនៅក្រោមលក្ខខណ្ឌ ដែលដាក់ចេញដោយអង្គជំនុំជម្រះ។ មូលដ្ឋានសំខាន់សម្រាប់សំណើនេះគឺការឃុំខ្លួនជនជាប់ចោទបន្តចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ ១៩៩៩ ដោយសមត្ថកិច្ចកម្ពុជា។ នៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន គឺថា មិនមានមូលដ្ឋានច្បាប់ទាល់តែសោះ ទាំងច្បាប់ជាតិ ឬច្បាប់អន្តរជាតិ សម្រាប់ការឃុំខ្លួនជនជាប់ចោទក្រោយខែឧសភា ឆ្នាំ២០០២។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌ UNTAC ឆ្នាំ១៩៩២ ច្បាប់ស្ដីអំពីរយៈពេលនៃការឃុំខ្លួនមុនជំនុំជម្រះក្ដី ឆ្នាំ១៩៩៩ និងមាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន លើជនជាប់សង្ស័យ ជនជាប់ចោទពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនអាចលើសពីបីឆ្នាំបានឡើយ។ តាមមាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងយុត្តិសាស្ត្រអន្តរជាតិ ចែងថា ការឃុំខ្លួនពីមុនចំពោះឧក្រិដ្ឋកម្មដូចគ្នា ក្រោមយុត្តាធិការជាតិ ត្រូវយកមកពិចារណា ក្នុងការផ្ដន្ទាទោស។ មេធាវីការពារក្ដីក៏បានស្នើសុំបន្ថែមឲ្យមានការប្រកាសថាប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានទោស ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់វិញនូវរយៈពេលដែលខ្លួនជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំង។ មេធាវីការពារក្ដីបានស្នើសុំបន្ថែមថា ប្រសិនបើជនជាប់ចោទត្រូវជាប់ទោស សុំឲ្យមានការកាត់បន្ថយទោស ជាសំណងចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវទទួលការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប[24]។ នៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនទាក់ទិនទៅនឹងសំណុំរឿងតុលាការយោធា មេធាវីការពារក្ដីបានលើកឡើងករណីជាថ្មីម្ដងទៀតរបស់ខ្លួន អំពីការបន្តឃុំខ្លួនជនជាប់ចោទ និងការឃុំខ្លួនដែលត្រូវបានពន្យារច្រើនហួសហេតុ[25]។

---

[24] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/7) និង ប្រ. ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/7.1), ទំព័រ 20-33 និងជាពិសេសទំព័រ 30, បន្ទាត់ 14-15 និង 31, បន្ទាត់ 19-23 (អង់គ្លេស)។ «Arguments supplémentaires de la Défense venant au soutien de ses demandes relatives à la question de la peine», ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39/3)។

[25] «Observations de la défense relatives au dossier militaire», 1 juin 2009 (ឯកសារ E39/4/2)។

៧. នៅក្នុងសារណាតបទៅនឹងសំណើនោះ សហព្រះរាជអាជ្ញាបញ្ជាក់ថា ភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទ ត្រូវបាន ស.ច.ស និង អ.ប.ជ ធ្វើការពិចារណារួចហើយ។ អ.វ.ត.ក គឺជាតុលាការកូនកាត់ ឯករាជ្យពីប្រព័ន្ធតុលាការជាតិ។ ដោយសារតែការឃុំខ្លួនពីមុនទៅលើជនជាប់ចោទដោយតុលាការយោធា មិនត្រូវបានធ្វើឡើងតាមសំណើរបស់សហព្រះរាជអាជ្ញានោះ ការរំលោភដែលត្រូវបានចោទប្រកាន់ណាមួយទៅលើសិទ្ធិជនជាប់ចោទដោយតុលាការជាតិ គឺមិនទាក់ទិនឡើយចំពោះមុខ អ.វ.ត.ក។ លើសពីនេះទៀត មិនមានកាលៈទេសៈប្រែប្រួលណាមួយដែលតម្រូវឲ្យមានការដោះលែងជនជាប់ចោទ ចាប់តាំងពីមានសេចក្តីសម្រេចរបស់ អ.ប.ជ រក្សាការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន[26]។ បន្ទាប់ពីបានពិនិត្យសំណុំរឿងតុលាការយោធា សហព្រះរាជអាជ្ញា អះអាងបញ្ជាក់ជាថ្មីថា កិច្ចដែលបំពេញដោយតុលាការយោធាមិនអាចត្រូវបានយកមកដាក់បន្ទុកទៅលើ អ.វ.ត.ក បានទេ។ សហព្រះរាជអាជ្ញា បដិសេធមិនធ្វើអត្ថាធិប្បាយ ទៅលើសំណុំរឿងតុលាការយោធា ដោយលើកទឡ្ហីករណ៍ថា ខ្លឹមសារនៅក្នុងសំណុំរឿងនោះមិនទាក់ទិនទៅនឹងសំណើរបស់ជនជាប់ចោទ សុំឲ្យមានការដោះលែងជនជាប់ចោទជាបន្ទាន់នោះឡើយ។

៨. ទោះបីជាមិនមានការជំទាស់ទៅនឹងការផ្តន្ទាទោសណាមួយ ដែលត្រូវពិចារណាទៅលើរយៈពេលដែលជាប់ឃុំពីមុនយ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនយល់ស្របឡើយ ដែលជនជាប់ចោទត្រូវមានសិទ្ធិទទួលបានការកាត់បន្ថយទោសបន្ថែមទៀត ដែលជាបច្ច័យនៃការរំលោភសិទ្ធិរបស់ជនជាប់ចោទនោះ។ អ.វ.ត.ក មិនតម្រូវឲ្យធ្វើការពិចារណាអំពីការរំលោភសិទ្ធិរបស់ជនជាប់ចោទកាលពីមុនដែលកើតចេញពីការឃុំខ្លួននៅក្នុងយុត្តាធិការផ្សេងគ្នាឡើយ[27]។ សិទ្ធិរបស់ជនជាប់ចោទ ក៏ត្រូវបានថ្លឹងថ្លែងផង

---

26 ប្រ. ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/7.1), ទំព័រ 33-38 (អង់គ្លេស)។

27 “សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំឲ្យបដិសេធសំណងបន្ថែមចំពោះជនជាប់ចោទ ដោយសារការឃុំខ្លួនបណ្តោះអាសន្នដោយខុសច្បាប់ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39/2)”។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE

ដែលទល់ទៅនឹងផលប្រយោជន៍របស់សហគមន៍អន្តរជាតិ នៅក្នុងការផ្តន្ទាទោសបុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទរំលោភបំពានដ៏ធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ[28]។

## ឃ. សំអាងហេតុ

### ក. យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការរំលោភសិទ្ធិជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់ ដែលកើតមានឡើងមុនពេលបង្កើត អ.វ.ត.ក។

៩. ខ្លឹមសារសំខាន់នៃសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីគឺថា រឿងក្តីរបស់ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក គឺមានអានុភាពជាការបន្តរឿងក្តីរបស់គាត់ពីតុលាការយោធា។ ការឃុំខ្លួនគាត់បណ្តោះអាសន្ននាពេលនោះ បានចាប់ផ្តើមនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ និងមិនមានមូលដ្ឋានអង្គច្បាប់ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០២[29]។

១០. អង្គជំនុំជម្រះយល់ឃើញថា អ.វ.ត.ក ដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គឺជាតុលាការមួយដែលត្រូវបានបង្កើតឡើងដាច់ដោយឡែក ឯករាជ្យ និង មានលក្ខណៈអន្តរជាតិ ។ ទោះបីជាឯកសារបង្កើត អ.វ.ត.ក បង្ហាញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ដែលមានស្រាប់យ៉ាងណាក៏ដោយ ក៏ អ.វ.ត.ក គឺជាស្ថាប័នមួយឯករាជ្យនិងដំណើរការដោយឯករាជ្យ នៅក្នុងរចនាសម្ព័ន្ធនេះ[30]។ ដោយតុលាការមួយនេះមានលក្ខណៈពិសេស

---

[28] ដូចដើងទំព័រខាងលើ។ សូមអាន «Observations supplémentaires des co-avocats des parties civiles (groupe 3) sur la demande de mise en liberté de Kaing Guek Eav, alias Duch», ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E39/1) (ការសង្កេតបន្ថែមទៅលើសំណើសុំឲ្យនៅក្រៅឃុំរបស់ជនជាប់ចោទ ក្នុងការរំលោភទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះ ដែលកម្រិតនូវការឆ្លើយតបរបស់ខ្លួនទៅនឹងសំណើបន្ថែមរបស់សហមេធាវីការពារក្តី ស្តីអំពីផលប៉ះពាល់នៃការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធាចំពោះការផ្តន្ទាទោស)។

[29] ប្រ. ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E1/7.1) ទំព័រ 22 បន្ទាត់ 9-13 (ភាសាអង់គ្លេស)។

[30] ច្បាប់ អ.វ.ត.ក មាត្រា ២ថ្មី។ មាត្រា ១២(១) កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

(“វិសាមញ្ញ”) និង ឯករាជ្យនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា អ.វ.ត.ក ត្រូវបានបង្កើតឡើងដាច់ដោយឡែកពី តុលាការកម្ពុជាដែលមានស្រាប់ និង កាត់សេចក្តីដោយផ្តាច់មុខទៅលើតែចុងចោទមួយក្រុមដែលត្រូវបានកំណត់យ៉ាងចង្អៀត សម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលមួយដែលបានកំណត់ជាក់លាក់។

១១. រចនាសម្ព័ន្ធរបស់ អ.វ.ត.ក គឺខុសគ្នាពីរចនាសម្ព័ន្ធតុលាការកម្ពុជាផ្សេងទៀត។ខណៈដែលនីតិវិធីរបស់ខ្លួនត្រូវអនុវត្តតាមច្បាប់កម្ពុជា អ.វ.ត.ក ក៏មានសិទ្ធិអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួនឲ្យស្របទៅតាមបទដ្ឋានអន្តរជាតិ ដែលពិចារណាទៅលើយន្តការពិសេសដែលចាំបាច់ដើម្បីវិនិច្ឆ័យសេចក្តីទៅលើឧក្រិដ្ឋកម្មធំៗ។ អ.វ.ត.ក នេះមានមន្ត្រីតុលាការបុគ្គលិកជាតិនិងអន្តរជាតិ ដែលមិនមានសមត្ថកិច្ចចូលរួម ឬ ធ្វើការវិនិច្ឆ័យសេចក្តីសម្រេចដែលត្រូវធ្វើដោយតុលាការកម្ពុជាឡើយ។ លើសពីនេះទៀត ចៅក្រមកម្ពុជានៅ អ.វ.ត.ក មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិបន្ថែម ពីលើសិទ្ធិដទៃទៀតដែលចៅក្រមកម្ពុជាមាន។ រីឯមាត្រា១១ នៃកិច្ចព្រមព្រៀងបានចែងមិនឲ្យមានការសុំលើកលែងទោស ឬ អនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឡើយ ដែលប្រការនេះអាចត្រូវបានស្នើសុំពីរាជរដ្ឋាភិបាលបានចំពោះតែការផ្តន្ទាទោសដែលត្រូវបានសម្រេចដោយតុលាការកម្ពុជាប៉ុណ្ណោះ។

១២. មិនមានមូលដ្ឋាននីតិវិធី សម្រាប់ចាប់ផ្តើមកិច្ចស៊ើបអង្កេតនៅតុលាការកម្ពុជា ហើយធ្វើសេចក្តីសន្និដ្ឋានកិច្ចស៊ើបអង្កេតទាំងនោះនៅចំពោះមុខ អ.វ.ត.ក ទេ។ ការចោទប្រកាន់នៅចំពោះមុខអ.វ.ត.ក គឺជាបុព្វសិទ្ធិផ្តាច់មុខរបស់ការិយាល័យសហព្រះរាជអាជ្ញា។មិនមានការជាប់ទាក់ទងសមត្ថកិច្ចរវាង អ.វ.ត.ក និងតុលាការដទៃទៀតដែលមាននៅក្នុងប្រព័ន្ធតុលាការកម្ពុជាទេ[31]។

---

តេយ្យ (“កិច្ចព្រមព្រៀង”) ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។ សូមអាន “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្កេកអ៊ាវ ហៅ ឌុច” ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ (ឯកសារ C5/45), កថាខណ្ឌ 19។

[31] មាត្រា ៣៦ថ្មី ច្បាប់អ.វ.ត.ក។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

១៣. មេធាវីការពារក្តីបានយកសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត នៃតុលាការយោធា ដែលបញ្ចប់ដំណើរការនីតិវិធីប្រឆាំងទៅនឹងជនជាប់ចោទនៅក្នុងតុលាការយោធា មកអះអាងចំពោះ អ.វ.ត.ក ថា ដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទនៅចំពោះមុខអ.វ.ត.ក គឺជាការបន្តដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ នៅតុលាការយោធា[32]។ ទោះបីជាយ៉ាងណាក៏ដោយ ដីកានេះចេញនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ ដែលមានរយៈពេលជិតមួយឆ្នាំបន្ទាប់ពីជនជាប់ចោទត្រូវបានផ្ទេរយកមកឃុំឃាំង នៅ អ.វ.ត.ក។ ដូច្នេះពិតណាស់ថា វាមិនមែនជាការផ្ទេររឿងក្តីនេះទេ។ ដីកានេះមិនមែនជាមូលដ្ឋានក្នុងការដោះលែងជនជាប់ចោទ បញ្ជូនទៅមន្ទីរឃុំឃាំង អ.វ.ត.ក ហើយដីកានេះក៏មិនមានអមមកជាមួយនូវសំណុំរឿងរបស់ជនជាប់ចោទ នៅតុលាការយោធាដែរ។ លើសពីនេះទៀត ការស៊ើបអង្កេតតាមផ្លូវតុលាការនៅចំពោះមុខ អ.វ.ត.ក បានចាប់ផ្តើមដំណាក់កាលនីតិវិធីថ្មី និងផ្សេងគ្នា ។

១៤. ការណ៍ដែលតុលាការយោធាបានចេញដីកាមុនៗរបស់ខ្លួន ដោយយោងទៅលើច្បាប់បង្កើត អ.វ.ត.ក មុនពេលដែល អ.វ.ត.ក ចាប់ផ្តើមដំណើរការនៅក្នុងខែមិថុនា ឆ្នាំ២០០៧ (បន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួន)នោះ មិនមែនជាការបង្ហាញអំពីការបន្តនិរន្តភាពរវាងការឃុំខ្លួនជនជាប់ចោទដែលចេញដោយតុលាការយោធា និង អ.វ.ត.ក ឡើយ។ មិនមានភស្តុតាង អំពីការជាប់ពាក់ព័ន្ធសមត្ថកិច្ចរបស់ អ.វ.ត.ក នៅក្នុងសំណុំរឿងតុលាការយោធារបស់ជនជាប់ចោទឡើយ និងជាពិសេស នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទាក់ទងទៅនឹងការឃុំខ្លួនជនជាប់ចោទ[33]។

---

[32] "ដីកាសម្រេច" ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ (តុលាការយោធាលេខ 139/08/DK, ឯកសារ E52/4.66)។

[33] សូមអាន ឧទាហរណ៍ ដីកាឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតតុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ (តុលាការយោធា លេខ 142/99, ឯកសារ E52/4.8), ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ (តុលាការយោធា លេខ 176/99, ឯកសារ E52/4.22), ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ (តុលាការយោធា លេខ 16/2002 DK, ឯកសារ E52/4.47) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៣ (តុលាការយោធា លេខ10/03/DK, ឯកសារ E52/4.48) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៤ (តុលាការយោធា លេខ 19/04/DK, ឯកសារ E52/4.54) ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ (តុលាការយោធា លេខ



E C C C * C E T C
TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE

00338877



១៥. ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មិនត្រឹមតែផ្តល់សិទ្ធិដល់ អ.វ.ត.ក ឱ្យអនុវត្តនីតិវិធីព្រហ្មទណ្ឌក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែក៏បានតម្រូវឱ្យ អ.វ.ត.ក បកស្រាយវិធានទាំងនេះ និងកំណត់អំពីភាពស្របគ្នានៃវិធានទាំងនោះទៅនឹងបទដ្ឋានអន្តរជាតិ ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងត្រូវបានអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ[34]។ លើសពីនេះទៀត អ.វ.ត.ក ត្រូវតែពិចារណាលើមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា“ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស.....”

១៦. ទោះបីជាការរំលោភលើសិទ្ធិជនជាប់ចោទ មិនអាចមានការជាប់ពាក់ព័ន្ធទៅនឹង អ.វ.ត.ក ក៏ដោយ ក៏យុត្តិសាស្ត្រអន្តរជាតិណែនាំថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានសិទ្ធិ និងកាតព្វកិច្ចក្នុងការពិចារណា លើនីត្យានុកូលភាពនៃការឃុំខ្លួនជនជាប់ចោទពីមុនបាន។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR នៅក្នុងរឿងក្តី Barayagwiza បានលើកឡើងថា ការរំលោភសិទ្ធិជនជាប់ចោទ ក្រោមច្បាប់ត្រូវតែបានទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលគាត់ស្នើសុំឱ្យដោះលែង ទោះបីជាការរំលោភសិទ្ធិនោះមិនអាចជាប់ពាក់ព័ន្ធនឹងតុលាការនោះក៏ដោយ[35]។ ច្បាប់យុត្តិ

---

08/05, ឯកសារ E52/4.57) ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ (តុលាការយោធា លេខ 05/06/DK, ឯកសារ E52/4.60) និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ (តុលាការយោធា លេខ 74/07, ឯកសារ E52/4.63)។

[34] មាត្រា៣៣ថ្មី ច្បាប់ អ.វ.ត.ក។ សូមអាន ឧទាហរណ៍ មាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាប្រទេសហត្ថលេខីមួយ ដែលចែងថា “គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួន តាមអំពើចិត្តបានឡើយ” ឬ “គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាម នីតិវិធីដែលមានចែងនៅក្នុងច្បាប់”។

[35] រដ្ឋអាជ្ញា ទល់នឹង *Barayagwiza,* សំណុំរឿងលេខ ICTR-97-19, សេចក្តីសម្រេច ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) កថាខណ្ឌ៨៥: “វាមិនសំខាន់ទេដែលថា ផ្នែកដ៏តូចមួយតែប៉ុណ្ណោះនៃរយៈពេលសរុបនៃការឃុំខ្លួនបណ្តោះអាសន្នបណ្តាលមកពីតុលាការនោះឡើយ ពីព្រោះនោះគឺជាតុលាការ - មិនមែនជាស្ថាប័នផ្សេងទៀតឡើយ - ដែលធ្វើការសម្រេចនៅពេលនេះទៅលើការទាមទាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។

00338878



សាស្ត្រអន្តរជាតិ ណែនាំបន្ថែមទៀតថា ប្រវត្តិជាប់ក្នុងឃុំពីមុនរបស់ជនជាប់ចោទអាចជាប់ពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចអំពីការផ្តន្ទាទោស។ ច្បាប់យុត្តិសាស្ត្រនេះក៏បានណែនាំផងដែរទៅលើកាលៈទេសៈ ដែលការរំលោភលើសិទ្ធិជនជាប់ចោទពីមុននោះ មានលក្ខណៈធ្ងន់ធ្ងរ ការរំលោភសិទ្ធិទាំងនោះអាចរារាំង ឬក៏បញ្ឈប់មិនឱ្យមានការអនុវត្តយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយផ្អែកទៅលើមូលហេតុនៃការរំលោភលើកិច្ចនៃនីតិវិធី និងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ[36]។

១៧. ដូច្នេះ វាជាការចាំបាច់ក្នុងការវាយតម្លៃថា តើការឃុំខ្លួនដោយតុលាការយោធាពីមុនគឺជាការរំលោភលើសិទ្ធិរបស់អ្នកស្នើសុំឬទេ ហើយប្រសិនបើមានការរំលោភសិទ្ធិមែននោះ ការទូទាត់អាចយកមកសុំអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន។

## ខ. នីត្យានុកូលភាពនៃដីការបស់តុលាការយោធា

១៨. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា ការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែធ្វើឡើងឱ្យស្របតាម "នីតិវិធី [កម្ពុជា] ដែលមានជាធរមាន" និងចែងថា "លក្ខខណ្ឌដើម្បីចាប់ខ្លួន និងឃុំខ្លួនជនត្រូវចោទត្រូវឱ្យស្របទៅនឹងច្បាប់ដែលមានជាធរមាន"[37]។ មាត្រា៣៨ នៃ

---

ដោយមិនខ្វល់ អំពីភាគីដទៃទៀតដែលអាចមានការទទួលខុសត្រូវ សេចក្តីសន្និដ្ឋានដែលមិនអាចជៀសវាងបានគឺថា សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានព័ត៌មានភ្លាមអំពីបទចោទប្រឆាំងរូបគាត់ គឺត្រូវបានរំលោភ"។

[36] សូមអាន ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង *Lubanga,* សំណុំរឿង លេខ ICC-01/04-01/06, សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការតវ៉ារបស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា១៩ (២) (ក) នៃលក្ខន្តិកៈ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាឧក្រិដ្ឋកម្មអន្តរជាតិ) ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ២៦-៣៥។ រដ្ឋអាជ្ញា ទល់នឹង *Barayagwiza,* សំណុំរឿង លេខ ICTR-97-19 សេចក្តីសម្រេច ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា) កថាខណ្ឌ៧៣: "ក្រោមទ្រឹស្តីនៃការរំលោភលើនីតិវិធី វាមិនសំខាន់ឡើយដែលស្ថាប័នមួយ ឬស្ថាប័នជាច្រើនទទួលខុសត្រូវចំពោះការរំលោភដែលត្រូវបានគេចោទប្រកាន់ទៅលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍"។

[37] មាត្រា២០ថ្មី, ២៣ថ្មី និង៣៣ថ្មី នៃច្បាប់អ.វ.ត.ក។

E C C C · TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងបន្ថែមថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"។

១៩. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានចូលជាធរមាន កាលពី ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧[38]។ មុនពេលអនុម័តច្បាប់នេះ ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធានាពេលនោះ ច្បាប់នីតិវិធីព្រហ្មទណ្ឌចំនួនពីរអាចត្រូវបានយកមកអនុវត្តជំនួស គឺ ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ ដែលត្រូវបានអនុម័តដោយអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាច្បាប់អ៊ុនតាក់ UNTAC LAW) និងច្បាប់នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣[39]។ នៅឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជា ក៏បានប្រកាសឱ្យប្រើច្បាប់ស្ដីអំពីរយៈពេលនៃការឃុំខ្លួនមុនពេលសវនាការឆ្នាំ១៩៩៩ផងដែរ ដែលបានដាក់ការកំណត់ឃុំខ្លួនជាបណ្ដោះអាសន្នរយៈពេល៣ឆ្នាំ ជាអតិបរមា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[40]។ ឃើញថា ជនជាប់ចោទត្រូវបានឃុំខ្លួនតាមច្បាប់

---

[38] មាត្រា២១០ ចែងថា "ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវឱ្យលើសពី១ឆ្នាំ នោះទេចំពោះបទល្មើសនីមួយៗ"។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

[39] "បទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល" ("ច្បាប់អ៊ុនតាក់") ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ (ជាពិសេស មាត្រា ២១)។ និងរដ្ឋកម្ពុជា (SOC) ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៣ (ជាពិសេស មាត្រា៦៤)។

[40] មាត្រា២១(១) នៃច្បាប់អ៊ុនតាក់ បានចែងថា "គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្ដី ឬមិនជាប់ឃុំក្ដី ត្រូវតែបានទទួលការកាត់ក្ដី យ៉ាងយូរបំផុតប្រាំមួយខែ ក្រោយពីថ្ងៃចាប់ខ្លួន"។ មាត្រា១ នៃច្បាប់ស្ដីពីថិរវេលានៃការឃុំខ្លួនមុន សវនាការ បានចែងថា: "នៅក្នុងកាលៈទេសៈណាក៏ដោយ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវឱ្យលើសពី៤ខែឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមសេចក្ដីសម្រេចរបស់ចៅក្រមដែលមានមូលហេតុ រយៈពេលនេះ អាចត្រូវបានបន្តរហូតដល់៦ខែ ក្នុងករណីមានការចាំបាច់ដើម្បីធ្វើការស៊ើបសួរ។ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ដែលប្រទេស



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ក្រោយនេះ អស់រយៈពេលជិត៨ឆ្នាំ ដូច្នេះហើយវាជាការឃុំខ្លួន ខុសច្បាប់រហូតដល់ពេលបញ្ជូនគាត់ទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ កាលពីខែកក្កដា ឆ្នាំ២០០៧។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា វាជាការពិបាកណាស់ក្នុងការកំណត់ឱ្យបានច្បាស់លាស់ ថាតើការឃុំខ្លួនខុសច្បាប់បានចាប់ផ្ដើម តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ឬថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩។

២០. នៅក្នុងអំឡុងពេលនៃការឃុំខ្លួននោះ មិនឃើញមានធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ និងស៊ីជម្រៅឡើយ និង មិនមានសរសេរសំអាងហេតុដែលជាមូលដ្ឋានច្បាប់សម្រាប់ការឃុំខ្លួននានានោះទេ[41]។ តាមសំណុំរឿងរបស់តុលាការយោធា ឃើញថា នៅពេលខ្លះការពន្យាររយៈពេលនៃការឃុំខ្លួនជនជាប់ចោទ ត្រូវបានបង្គាប់ដោយព្រះរាជអាជ្ញាតែម្នាក់ឯងប៉ុណ្ណោះ មិនមែនដោយចៅក្រមស៊ើបអង្កេតនោះទេ[42]។ លើសពីនេះទៀត ច្បាប់

---

កម្ពុជាជាប្រទេសហត្ថលេខីនោះ ការឃុំខ្លួនបណ្ដោះអាសន្នខាងលើអាចត្រូវបានពន្យាថិរវេលារហូតដល់១ឆ្នាំ។ ប៉ុន្តែការពន្យារថិរវេលានេះ សរុបទៅមិនត្រូវឱ្យលើសពី ៣ឆ្នាំ នោះទេ" ។

[41] ផ្ដើមចេញពីការយល់ឃើញនៅក្នុងសំណុំរឿងរបស់តុលាការយោធា បង្ហាញឱ្យឃើញថា ការស៊ើបសួរមានការសួរយកចម្លើយជនជាប់ចោទជាសំខាន់។ សំណុំរឿងមានការកាត់តព័ត៌មានមួយចំនួននិងបញ្ជីឈ្មោះអ្នកទោសបរទេសដែលត្រូវបានផ្ញើទៅតុលាការយោធាពីស្ថានទូតអូស្ត្រាលី (ឯកសារ E52/4.21 និង E52/4.20)។
មានតែសាក្សីចំនួន២រូប ប៉ុណ្ណោះដែលទំនងជាត្រូវបានសួរយកចម្លើយ ក្នុងរយៈពេល៨ឆ្នាំ នៃការឃុំខ្លួនជនជាប់ចោទ ("កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី" ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ (ឯកសារ E52/4.19) និង កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ (ឯកសារ E52/4.49)។ ពុំមានដីកាឃុំខ្លួនណាមួយសម្អាងលើហេតុផលច្បាប់នោះទេ។ ឧទាហរណ៍: ដីកាឃុំខ្លួន ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ (ឯកសារ E52/4.8 និង E52/4.22 ) បានបង្គាប់ឱ្យមានការឃុំខ្លួនជនជាប់ចោទ "ដើម្បីធ្វើការស៊ើបសួរ"។ ដីកាឃុំខ្លួនចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០២ (ឯកសារ E52/4.48) មិនបានចែង
អំពីមូលហេតុដែលត្រូវធ្វើយុត្តិកម្មការឃុំខ្លួននោះទេ។ លិខិតសុំពន្យារពេលស៊ើបអង្កេតដែលនាំឱ្យមានការបង្គាប់ឱ្យបន្តការឃុំខ្លួនដោយព្រះរាជអាជ្ញានៃតុលាការយោធា នៅពេលខ្លះបានយោងតែទៅលើ "ភាពស្មុគ្រស្មាញនៃសំណុំរឿងក្ដី" (សូមមើលឧទាហរណ៍: លិខិតសុំពន្យារពេលស៊ើបអង្កេត ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០ ឯកសារ E52/4.33 និងចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ ឯកសារ E52/4.35។

[42] "លិខិតសុំពន្យារពេលស៊ើបអង្កេត" របស់ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០ (តុលាការយោធា លេខ ៥០០:២០០០ ឯកសារ E52/4.33) និងចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ (តុលាការយោធា



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

មួយចំនួនដែលតុលាការយោធាយកមកប្រើនោះ ឃើញថា យកមកប្រើដោយអានុភាពប្រតិសកម្ម ដោយរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទ តាមច្បាប់នៃព្រះរាជណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ[43]។

២១. ហេតុដូច្នេះហើយ អង្គជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនជនជាប់ចោទពីមុន នៅតុលាការយោធា គឺជាការបំពានច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែលប្រើប្រាស់នាពេលនោះ។ ការឃុំខ្លួននោះក៏បានបំពានផងដែរទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីក្នុងរយៈពេលមួយសមស្របដែលជាសិទ្ធិត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងរំលោភបំពានផងដែរលើការឃុំខ្លួនជនជាប់ចោទស្របតាមបញ្ញត្តិច្បាប់។

## គ. លក្ខខណ្ឌសម្រាប់ការឃុំខ្លួនជាបណ្តោះអាសន្ននៅអង្គជំនុំជម្រះសាលាដំបូង

២២. ទោះបីជាមានការរកឃើញអំពីភាពខុសច្បាប់ទាក់ទងនឹងការឃុំខ្លួនជនជាប់ចោទ ដោយតុលាការយោធាខាងលើនេះ អាចផ្តល់សិទ្ធិឲ្យជនជាប់ចោទទទួលបាននូវការទូទាត់ នៅដំណាក់កាលបន្ទាប់ទៀតក៏ដោយ ក៏បញ្ហាទាក់ទងនឹងការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញត្រឹមត្រូវយ៉ាងណានោះ ក៏ត្រូវតែវាយតម្លៃផងដែរស្របតាមលក្ខណៈវិនិច្ឆ័យដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។

២៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន៨២ នៃវិធានផ្ទៃក្នុង បានបញ្ញត្តអំពីការឃុំខ្លួនជនជាប់ចោទដោយអង្គជំនុំជម្រះសាលាដំបូង។ វិធាន៨២(១) នៃវិធានផ្ទៃក្នុងចែងថា

---

លេខ ១៧/០១ ឯកសារ E52/4.35)។ និង "ដីកាសម្រេចពន្យាររយៈពេលស៊ើបអង្កេត" របស់ព្រះរាជអាជ្ញានៃតុលាការយោធា ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ (តុលាការយោធា លេខ ០១៣/២០០០ ឯកសារ E52/4.34) និង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ (តុលាការយោធា លេខ០១៥/២០០១ ឯកសារ E52/4.46)។

[43] សូមមើលឧទាហរណ៍: ដីកាឃុំខ្លួន ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ (ឯកសារ E52/4.8) ដែលឃុំខ្លួនជនជាប់ចោទពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តកាលពីឆ្នាំ១៩៧៥ តាមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ដែលបានចូលជាធរមាននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ និងក្រិត្យច្បាប់លេខ២ ដែលបានចូលជាធរមាននៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

"ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែល រហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានសម្រេចសេចក្តី លើកលែងតែករណីដែលមានចែងនៅក្នុងអនុវិធាន២ ខាងក្រោម"។

២៤. វិធាន៨២(២) នៃវិធានផ្ទៃក្នុង ចែងថា គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ។ នៅពេលដែលអង្គជំនុំជម្រះបានទទួលសំណើសុំដោះលែងលើកទីមួយ អង្គជំនុំជម្រះមានកាតព្វកិច្ចពិនិត្យថាតើរាល់លក្ខខណ្ឌអង្គហេតុ និងអង្គច្បាប់ទាំងអស់ត្រូវបានបំពេញនៅដំណាក់កាលនៃដំណើរការនីតិវិធីថ្មីនេះដែរឬទេ។ មាត្រា៨២(៤) ចែងថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំដោះលែងរបស់ខ្លួន ជនជាប់ចោទអាចដាក់ពាក្យសុំសារជាថ្មីម្តងទៀត តែនៅពេលណាដែលស្ថានភាព របស់ខ្លួនមានការប្រែប្រួលប៉ុណ្ណោះ ចាប់តាំងពីពេលដែលពាក្យសុំមុនត្រូវបានបដិសេធ។

២៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បច្ចុប្បន្នេះជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន អនុលោមតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនិងដីកាឃុំខ្លួនដែលពាក់ព័ន្ធ[44]។ នៅខែ ធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានរកឃើញថា ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នគឺត្រឹមត្រូវ ដោយសំអាងលើតម្រូវការ ក្នុងការរារាំងកុំឲ្យជនជាប់ចោទគម្រាមកំហែងដល់សាក្សី ដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទនៅក្នុងពេលដំណើរការនីតិវិធី ការការពារសុវត្ថិភាពដល់ជនជាប់ចោទ និង ការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ[45]។ អង្គជំនុំជម្រះយល់ឃើញថា ករណីឥឡូវនេះ មានតែលក្ខខណ្ឌចំនួនបីនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ

---

[44] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42) និង"ដីកាឃុំខ្លួន" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨(ឯកសារ D99/3/43) ។

[45] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ (ឯកសារ C5/45) កថាខណ្ឌ ៣០-៣៦។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

ដែលត្រូវយកមកអនុវត្តនៅដំណាក់កាលជំនុំជម្រះក្តីនេះ[46]។ អង្គជំនុំជម្រះយល់ឃើញថា សេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងការចៀសវាងកុំឲ្យមានការគេចវេស ភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និង ការការពារសុវត្ថិភាពដល់ជនជាប់ចោទ នៅតែ មានសុពលភាពនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ[47]។ ការព្រួយបារម្ភទាំងនេះ មិនមានការថយចុះទេ ចាប់តាំងពីមានដីកាបង្គាប់ចុងក្រោយនោះហើយ វាហាក់ដូចជាមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ក្នុងការដោះលែងជនជាប់ចោទជាបណ្តោះអាសន្ននៅឡើយទេ។

២៦. ទីបញ្ចប់ យោងតាមវិធាន ២១(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនជនជាប់ចោទគឺត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ជាពិសេស តម្រូវការក្នុងការធានាអំពីវត្តមានរបស់ជនជាបចោទ និងមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ។ ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនជនជាប់ចោទ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានចូលសួរសុខទុក្ខជាទៀងទាត់ដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ កត់សម្គាល់ឃើញថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការចូលសួរសុខទុក្ខ កត់សម្គាល់ឃើញថា ជនជាប់ចោទស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ និងកត់សម្គាល់ឃើញថា ជាទូទៅ ស្ថានភាពរបស់ជនជាប់ចោទគឺគោរពតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស។

---

[46] វិធាន ៦៣(៣) ដែលបានរាយនូវលក្ខខ័ណ្ឌដែលសហចៅក្រមស៊ើបសួរអាចចេញដីកាឃុំខ្លួនបណ្តោះអាសន្ន (ពោលគឺក្នុងករណីចាំបាច់ក្នុងការរារាំងការគាបសង្កត់របស់សាក្សី ការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត ការថែរក្សាភស្តុតាង ឬការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣(៣)(ខ)( i-v)) ក៏អាចយកធ្វើជាការណែនាំ ដល់អង្គជំនុំជម្រះសាលាដំបូងផងដែរ។

[47] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ (ឯកសារ C5/45) កថាខណ្ឌ ៣៧-៤១ (ដោយកត់សម្គាល់ឃើញថា "មានកត្តាជាច្រើនបង្ហាញថា ជនជាប់ចោទបានប្រើប្រាស់វិធានការផ្សេងៗដើម្បីបិទបាំងពីអតីតកាលរបស់គាត់ រួមទាំងការដូរឈ្មោះ ដូរមុខរបរ និងទីលំនៅ")។

## ឃ. ការទូទាត់ចំពោះរយៈពេលនៃការឃុំខ្លួន និង សំណង

២៧. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួនរួចមកហើយ យោងតាមមាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[48]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា ក្នុងករណីរកឃើញថាមានពិរុទ្ធភាព រយៈពេលដែលបានជាប់ឃុំ ក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ ចាប់តាំងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ មកនោះ នឹងត្រូវយកមកទូទាត់ឱ្យជនជាប់ចោទនៅពេលផ្តន្ទាទោសណាមួយ។

២៨. អង្គជំនុំជម្រះទទួលស្គាល់ថា តាមបទបញ្ញត្តិដូចគ្នានេះ ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលបានជាប់ឃុំ ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ដោយសារមិនបានយកជនជាប់ចោទទៅជំនុំជម្រះដោយតុលាការយោធា[49]។ ដោយសារតុលាការយោធាយល់ឃើញថា ជាការបញ្ចប់សមត្ថកិច្ចលើរឿងក្តីនេះ ជនជាប់ចោទនឹងមិនត្រូវបានយកទៅជំនុំជម្រះនៅតុលាការយោធាទៀតទេ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទត្រូវបានឃុំខ្លួននៅតុលាការយោធា ដើម្បីធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ ដែលស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងការចោទប្រកាន់ដែលកំពុងត្រូវបានពិចារណានៅក្នុងការជំនុំជម្រះក្តីនេះ។

២៩. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ប្រសិនបើរកឃើញថា មានពិរុទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបានជាសំណងនូវការទូទាត់ ចំពោះរយៈពេលដែលបានជាប់ឃុំក្រោមសមត្ថកិច្ចរបស់តុលាការយោធា គឺចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។

---

[48] មាត្រា៥០៣ បានចែងថា "រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នត្រូវគិតបញ្ចូលទៅក្នុងទោសដែលសម្រេចដោយតុលាការ [...]"។

[49] "ដីកាសម្រេច" របស់ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ (តុលាការយោធា លេខ ១៣៩/០៨ ដ.ក ឯកសារ E52/4/66)។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

៣០. ដោយបានសន្និដ្ឋានថា ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធា ឃើញថា បានបំពានច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាជាធរមាននាពេលនោះ និងមានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទនោះ ពេលនេះ អង្គជំនុំជម្រះពិចារណាអំពីការទូទាត់ដែលត្រូវយកមកអនុវត្តចំពោះបច្ច័យដែលកើតចេញមកពីការរំលោភបំពានសិទ្ធិទាំងនេះ។

៣១. អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គូស្លាវី ICTY) បានគូសបញ្ជាក់ថា នៅពេលធ្វើការពិចារណាអំពីការទូទាត់ដោយសមរម្យចំពោះការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់ "តុល្យភាពត្រូវតែ ... មានជានិច្ចរវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងឧត្តមប្រយោជន៍របស់សហគមន៍អន្តរជាតិ នៅក្នុងការចោទប្រកាន់បុគ្គលដែលបានរំលោភបំពានធ្ងន់ធ្ងរច្បាប់មនុស្សធម៌អន្តរជាតិ"[50]។

៣២. ការរំលោភលើសិទ្ធិរបស់ជនជាប់ចោទដោយសមត្ថកិច្ចផ្សេង នឹងមានការជាប់ពាក់ព័ន្ធចំពោះតុលាការអន្តរជាតិ តែក្នុងករណីដែលមានកិច្ចរួមគ្នា រវាងតុលាការអន្តរជាតិ និងសមត្ថកិច្ចផ្សេងទាំងនោះប៉ុណ្ណោះ ចំពោះការរំលោភបំពានសិទ្ធិទាំងនោះ[51]។

---

[50] រឿងក្តី រដ្ឋអាជ្ញា តទល់ Nikolic សំណុំរឿងលេខ IT-94-2-AR73 "សេចក្តីសម្រេចអំពីបណ្តឹងបន្ទាន់បង្គំពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការចាប់ខ្លួន" (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ កថាខណ្ឌ ៣០។

[51] សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់ Rwamakuba សំណុំរឿងលេខ ICTR-98-44-T "សេចក្តីសម្រេចអំពីសំណើរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការចាប់ខ្លួននិងការឃុំខ្លួនជនជាប់ចោទខុសច្បាប់" (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR) ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ កថាខណ្ឌ ៣០: "អង្គជំនុំជម្រះសាលាដំបូងមិន... ពិចារណាអំពីថា ចាប់ពីថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៥ រហូតដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៥ នៅពេលដែលព្រះរាជអាជ្ញាបានជូនដំណឹងដល់សមត្ថកិច្ចណាមីប៊ៀឱ្យបានដឹងថា ជនជាប់ចោទស្ថិតនៅក្នុងមន្ទីរឃុំឃាំងរបស់ពួកគេនោះ តុលាការបានទទួលខុសត្រូវចំពោះការឃុំខ្លួនជនជាប់ជាប់នោះទេ។ តុលាការមិនមានយុត្តាធិការទៅលើលក្ខខ័ណ្ឌនៃរយៈពេលនៃការឃុំខ្លួននោះទេ ការជជែកតវ៉ាណាមួយពាក់ព័ន្ធនឹងរឿងនេះ ត្រូវធ្វើឡើងនៅចំពោះមុខយុត្តាធិការណាមីប៊ៀន"។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C B T C

៣៣. ទ្រឹស្តីស្តីពីការរំលោភបំពាននីតិវិធី មានការធានាបន្ថែមដល់សិទ្ធិរបស់ជនជាប់ចោទ និង អាចយកមកអនុវត្តបាន ទោះបីជានៅក្នុងកាលៈទេសៈដែលមិនមានកិច្ចរួមគ្នា រវាងតុលាការព្រហ្មទណ្ឌអន្តរជាតិនិងសមត្ថកិច្ចផ្សេងក៏ដោយ[52]។ ទ្រឹស្តីនេះដែលអាចនឹងតម្រូវឱ្យតុលាការបដិសេធមិនអនុវត្តយុត្តាធិការរបស់ខ្លួនចំពោះរឿងក្តីជាក់លាក់ណាមួយ ឬ មួយត្រូវបានធ្វើការបកស្រាយយ៉ាងចង្អៀត និងត្រូវបានកម្រិតចំពោះករណីដែលការប្រព្រឹត្តខុសច្បាប់ដែលជាបញ្ហាចោទគឺដូចជាការធ្វើឱ្យវិធានច្បាប់មិនល្អទាល់តែសោះ ក្នុងការនាំយកជនជាប់ចោទទៅជំនុំជម្រះនោះ[53]។ ចំពោះករណីដែលការរំលោភបំពានសិទ្ធិដែលជាបញ្ហានោះមិនជាប់ពាក់ព័ន្ធនឹងតុលាការអន្តរជាតិ ក៏ទ្រឹស្តីនេះហាក់ដូចជាត្រូវបានរឹតបន្តឹងចំពោះការធ្វើទារុណកម្ម ឬ ការធ្វើបាបយ៉ាងធ្ងន់ធ្ងរ ដោយសមត្ថកិច្ចផ្សេងហើយជាធម្មតាភាគច្រើន ត្រូវបានគេយកមកអនុវត្តចំពោះការចាប់ខ្លួន និង ការផ្ទេរសមត្ថកិច្ច[54]។

៣៤. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងរឿងក្តីLubanga បានពិចារណាអំពីភាពស្របច្បាប់នៃការឃុំខ្លួនជាបណ្តោះអាសន្ន ដែលត្រូវបានបង្គាប់ដោយអង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយគិតទៅដល់ទ្រឹស្តីនេះដែលមានការចោទប្រកាន់ថា ជនជាប់ចោទត្រូវបានឃុំខ្លួនដោយខុសច្បាប់ដោយសមត្ថកិច្ចជាតិ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឯកភាពថា មិនមានភស្តុតាងណា

---

[52] រឿងក្តី រដ្ឋអាជ្ញា តទល់ Barayagwiza សំណុំរឿងលេខ ICTR-97-19 សេចក្តីសម្រេចចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ (អង្គជំនុំជម្រះសាលា ដំបូងនៃតុលាការ ICTR) កថាខណ្ឌ ៧៣០: "ដោយមានការបំពានលើទ្រឹស្តីនៃរឿងក្តីនេះ មិនមិនភាពពាក់ព័ន្ធទេដែលអង្គភាពមួយឬច្រើនទទួលខុសត្រូវចំពោះការរំលោភលើសិទ្ធិរបស់ដើមបណ្តឹងនោះ"។

[53] រឿងក្តី រដ្ឋអាជ្ញា តទល់ Lubanga រឿងក្តីលេខ ICC-01/04-01/06 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចអំពីការតវ៉ាទៅនឹងយុត្តាធិការរបស់តុលាការរបស់មេធាវីការពារក្តី ស្របតាមមាត្រា ១៩(២) នៃលក្ខន្តិកៈចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ (អង្គជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០. ៣៧ (ដោយយល់ឃើញថា ក្នុងករណីដែលការកាត់សេចក្តីដោយយុត្តិធម៌មិនអាចធ្វើបានដោយសារតែការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទធ្វើដោយអ្នកចោទប្រកាន់គាត់នោះ កម្មវត្ថុនៃរឿងក្តីមិនត្រូវបានសម្រេច រីឯរឿងក្តីត្រូវគេបញ្ឈប់)។

[54] រឿងក្តី រដ្ឋអាជ្ញា តទល់ Nikolic សំណុំរឿងលេខ IT-94-2-AR73 "សេចក្តីសម្រេចអំពីបណ្តឹងបន្ទាន់បង្ហាញពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការចាប់ខ្លួន" (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៣ កថាខណ្ឌ ៣០។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

មួយបង្ហាញថា ការចាប់ខ្លួននិងការឃុំខ្លួន Lubanga មុនថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ គឺជាលទ្ធផលនៃកិច្ចរួមគ្នារវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងសមត្ថកិច្ចសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោទេ ឬ ថា រូបគាត់ត្រូវបានធ្វើ ទារុណកម្ម ឬត្រូវបានគេធ្វើបាបយ៉ាងធ្ងន់ធ្ងរនៅពេលណាមួយនោះទេ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នេះ បានសន្និដ្ឋានថា អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានការភាន់ច្រឡំក្នុងការសម្រេចឃុំខ្លួន Lubanga ជាបណ្ដោះអាសន្ននៅតុលាការព្រហ្មទណ្ឌអន្តរជាតិនេះទេ[55]។ អង្គជំនុំជម្រះយល់ឃើញថា បើទោះបីជាការឃុំខ្លួនជនជាប់ចោទពីមុនត្រូវបានចាត់ទុកថាជាការរំលោភលើសិទ្ធិរបស់គាត់យ៉ាងពិតប្រាកដក៏ដោយ អវត្តមានការចោទប្រកាន់អំពីការធ្វើទារុណកម្ម ឬ ពីការធ្វើបាបយ៉ាងធ្ងន់ធ្ងរដោយសមត្ថកិច្ចជាតិទេនោះ ចំណុចនេះឃើញថាមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការរារាំង ការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការបង្គាប់ឱ្យមានការឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្នបានទេ។

៣៥. ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស រ៉្វាន់ដា(ICTR) ណែនាំថា ទោះបីជាក្នុងករណីដែលការរំលោភបំពានសិទ្ធិទាំងនេះ មិនអាចជាប់ពាក់ព័ន្ធនឹងតុលាការអន្តរជាតិឬមិនទុកថាជាការរំលោភលើដំណើរការនីតិវិធីក៏ដោយ ក៏ជនជាប់ចោទអាច មានសិទ្ធិស្នើសុំការទូទាត់សំណងចំពោះការរំលោភបំពានលើសិទ្ធិរបស់គាត់ដោយសមត្ថកិច្ចជាតិបាន[56]។ ការរំលោភ

---

[55] រឿងក្ដី រដ្ឋអាជ្ញា តទល់ Lubanga រឿងក្ដីលេខ ICC-01/04-01/06 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្ដីសម្រេចអមបីការតវ៉ាទៅនឹងយុត្តាធិការរបស់តុលាការរបស់មេធាវីការពារក្ដី ស្របតាមមាត្រា ១៩(២) នៃលក្ខន្តិកៈចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ (អង្គជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កឋាខណ្ឌ ៩-១០, ៤២-៤៣ (បានបង្ហាញពីយល់ឃើញថារបស់អង្គបុរេជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិថា នៅពេលដែលគ្មានបណ្ដឹងរួមរវាងព្រះរាជអាជ្ញានៃ ICC និងសមត្ថកិច្ចជាតិទេនោះ ការឃុំខ្លួនពីមុនដែលធ្វើដោយសមត្ថកិច្ចបន្ទាប់នោះ មិនប៉ះពាល់ដល់បញ្ហានៃការបំពានដំណើរការដែលគ្មានភស្តុតាងដើម្បីបង្កើតឱ្យមាននូវការធ្វើទារុណកម្ម ឬការធ្វើបាបធ្ងន់ធ្ងរនោះទេ)។

[56] រឿងក្ដី រដ្ឋអាជ្ញា តទល់ Barayagwiza សំណុំរឿងលេខ ICTR-97-19 សេចក្ដីសម្រេចចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ (អង្គជំនុំជម្រះសាលា ដំបូងនៃតុលាការ ICTR) កឋាខណ្ឌ ៧៣០: "វាមិនមានភាពពាក់ព័ន្ធគ្នាទេដែលមានតែមួយផ្នែកតូចនៃរយៈពេលនៃការឃុំខ្លួនសរុបប៉ុណ្ណោះអាចមានការពាក់ព័ន្ធនឹងតុលាការ -ដោយសារតែវាជាតុលាការ - ហើយមិនមែនជាស្ថាប័នផ្សេងនោះ - តុលាការនោះកំពុងតែវិនិច្ឆ័យទៅលើការទាមទាររបស់ដើមបណ្ដឹងឧទ្ធរណ៍។

បំពានសិទ្ធិទាំងនេះ ត្រូវបានលើកយកមកដោះស្រាយ ភាគច្រើន នៅដំណាក់កាលពិចារណាអំពីទោស។ ច្បាប់យុត្តិសាស្ត្រនេះណែនាំថា ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព ជនជាប់ចោទមិនត្រឹមតែមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេល ដែលត្រូវបានជាប់ឃុំឃាំងប៉ុណ្ណោះទេ ថែមទាំងមានសិទ្ធិទទួលបាននូវការកាត់បន្ថយទោសថែមទៀតផង ដោយសារតែការរំលោភលើសិទ្ធិរបស់ជនជាប់ចោទកាលពីមុន។

៣៦. ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ដែល អង្គជំនុំជម្រះនឹងត្រូវយកមកសម្រេចនៅដំណាក់កាលសម្រេចអំពីទោសចំពោះរយៈពេល ដែលគាត់ជាប់ឃុំឃាំងដោយខុសច្បាប់នៅតុលាការយោធា ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

៣៧. ក្នុងករណី ដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចខ្លួនពីបទចោទប្រកាន់ ច្បាប់យុត្តិសាស្ត្រអន្តរជាតិបានណែនាំថា ជនជាប់ចោទមានសិទ្ធិទាមទារសំណងនៅចំពោះមុខសមត្ថកិច្ចជាតិ ដែលត្រូវទទួលខុសត្រូវចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទនេះ[57]។ ប្រសិនបើត្រូវ បានសម្រេច ឱ្យរួចខ្លួនពីបទចោទប្រកាន់ ជនជាប់ចោទអាចនឹងមានសិទ្ធិទាមទារសំណងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចំពោះរយៈពេលដែល

---

ទោះបីជាភាគីផ្សេងអាចមានការទទួលខុសត្រូវក៏ដោយ សេចក្តីសន្និដ្ឋានដែលជៀសមិនរួចគឺថា សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ដែលនឹងត្រូវគេជូនពត៌មានអំពីការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ក្នុងពេលឆាប់ៗនោះ គឺត្រូវបានគេរំលោភបំពាន”។

[57] រឿងក្តី រដ្ឋអាជ្ញា តទល់ Rwanmakuba សំណុំរឿងលេខ ICTR-98-44-T “សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីទាក់ទងនិងការចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទដោយខុសច្បាប់” (អង្គជំនុំជម្រះសាលា ដំបូងនៃតុលាការ ICTR) ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០០ កថាខណ្ឌ ៣០ (ដោយសារតែ ICTR មិនទទួលខុសត្រូវចំពោះការឃុំខ្លួនជនជាប់ចោទនៅចំពោះមុខអាជ្ញាធរ Namibian រាល់ការប្តឹងទាក់ទងនិងបញ្ហានេះត្រូវធ្វើឡើងនៅចំពោះមុខតុលាការ Namibian )។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ត្រូវបានឃុំខ្លួន ព្រមទាំងការរំលោភលើសិទ្ធិរបស់គាត់ខណៈពេលស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៃតុលាការយោធាកម្ពុជា។

**តាមរយៈសម្អាងហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង:**

**បដិសេធ** សំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំនេះ។

**បង្គាប់ថា** ជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនជាបន្តទៀត នៅក្នុងអំឡុងពេលសវនាការ។

**រកឃើញថា** ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធាគឺមានកំហុសក្នុងការអនុវត្តច្បាប់នីតិវិធី រំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដូច្នេះហើយ ការឃុំខ្លួននេះមិនត្រឹមត្រូវតាមច្បាប់ទេ។

**ប្រកាសថា** ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់តុលាការយោធា និងចំពោះការរំលោភលើសិទ្ធិរបស់គាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងតាមច្បាប់អន្តរជាតិទូទៅ។

**កត់សម្គាល់ថា** ប្រសិនបើត្រូវបានសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់នោះ ជនជាប់ចោទអាចទាមទារសំណងសមស្របចំពោះរយៈពេល ដែលត្រូវបានឃុំខ្លួននៅតុលាការយោធា និងចំពោះការរំលោភសិទ្ធិរបស់គាត់នៅតុលាការជាតិ។

**ប្រកាសថា** ប្រសិនបើរកឃើញថាមានពិរុទ្ធភាព នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេល ដែលត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺចាប់តាំងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដោយអនុវត្តតាមមាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

TRIAL CHAMBER · CHAMBRE DE PREMIÈRE INSTANCE · E C C C · E T C

**ប្រកាសបន្ថែមថា** ប្រសិនបើរកឃើញថាមានពិរុទ្ធភាព នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួន ក្រោមសមត្ថកិច្ចរបស់តុលាការយោធា គឺចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ។

**ពន្យារនូវការសម្រេច** លើបញ្ហានៃចរិតលក្ខណៈនិងទំហំនៃសំណងបន្ថែម ដែលជាបច្ច័យនៃការរំលោភលើសិទ្ធិរបស់ជនជាប់ចោទដល់អង្គជំនុំជម្រះ ដើម្បីពិចារណានៅពេលធ្វើការសម្រេចសេចក្តីអំពីទោស ប្រសិនត្រូវយកមកពិចារណា។

ភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

E C C C E T C

**និល ‑ ណុន**